ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

ជូនចំពោះ
## លោកជំទាវ សួស ណារ៉ា ហ៊ឹម ឆែម ព្រមទាំងក្រុមគ្រួសារ

ខ្ញុំនិងក្រុមគ្រួសារ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីក្តុកក្តួលរន្ធត់ចិត្តយ៉ាងក្រៃលែង ដោយបានទទួលដំណឹងថា ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ដែលបានទទួលមរណភាពនៅថ្ងៃសៅរ៍ ១០កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១០:៥៥នាទីព្រឹក ក្នុងជន្មាយុ ៨២ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ឯកឧត្តម **ហ៊ឹម ឆែម** គឺជាការបាត់បង់នូវស្វាមី ឪពុកនិងជីតាប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជាការបាត់បង់វីរជនដ៏ឆ្នើមមួយរូបដែលពោរពេញដោយឆន្ទៈ មនសិការការងារក្នុងការបម្រើជាតិ សាសនា ព្រះមហាក្សត្រ ពិសេសការរួមចំណែករបស់ឯកឧត្តមក្នុងការលើកស្ទួយវិស័យវប្បធម៌ ធម្មការនិងសាសនាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំនិងក្រុមគ្រួសារ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកប្បការជាមួយលោកជំទាវ សួស ណារ៉ា ហ៊ឹម ឆែម ព្រមទាំងក្រុមញាតិគ្រួសារ។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធឯកឧត្តម **ហ៊ឹម ឆែម** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ** និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃអាទិត្យ ១១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ប្រាំ សុខា**